សូមបញ្ចេញមតិការពារ សិទ្ធិនិងផលប្រយោជន៍ របស់កុមារ



អាសយដ្ឋានទំនាក់ទំនង ដើម្បីស្នើសុំជំនួយគតិយុត្តិសម្រាប់កុមារ

មជ្ឈមណ្ឌលជំនួយគតិយុត្តិរដ្ឋ ស្ថិតក្រោមមន្ទីរយុត្តិធម៌រាជធានី ខេត្ត និងក្រុងដែលស្ថិតក្រោមមជ្ឈិម។

អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាផ្នែកច្បាប់ ដែលចូលរួមអនុវត្តជំនួយគតិយុត្តិ។

:អាសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានប្រកាសជាសាធារណៈនៅ៖

- **គេហទំព័រនីតិកម្មជាតិ**
  https://phapluat.gov.vn/
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់ក្រសួងយុត្តិធម៌**
  https://dstrogiupphaply.moj.gov.vn/all/searchOrganization
- **គេហទំព័រព័ត៌មានអេឡិចត្រូនិកស្តីពីជំនួយគតិយុត្តិនៅប្រទេសវៀតណាម**
  https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់មន្ទីរយុត្តិធម៌នៅមូលដ្ឋាន**



លោកអ្នកអាចទាក់ទងតាមមធ្យោបាយខាងក្រោម ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖

ខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីជំនួយគតិយុត្តិ

១៨០០១២៣៣

(Cước gọi miễn phí)

ទាញយកកម្មវិធីទូរស័ព្ទចល័តស្តីពីជំនួយគតិយុត្តិ

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ Android

កូដ QR សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ iOS

BỘ TƯ PHÁP

CHÍNH PHỦ NHẬT BẢN

QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN

NGÂN HÀNG THẾ GIỚI

ការផ្តល់ជំនួយគតិយុត្តិសម្រាប់កុមារ

TRỢ GIÚP PHÁP LÝ

យោងតាមមាត្រា ៧ នៃច្បាប់ស្តីពីការផ្តល់ជំនួយគតិយុត្តិ៖
កុមារ (ជាមនុស្សដែលមានអាយុក្រោម ១៦ ឆ្នាំ) គឺជាក្រុមមុខសញ្ញាទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃពីរដ្ឋ។



TRUNG TÂM TRỢ GIÚP PHÁP LÝ NHÀ NƯỚC



តើការផ្តល់ជំនួយគតិយុត្តិសម្រាប់កុមារជាអ្វី?

នោះគឺជាការផ្តល់សេវាជំនួយគតិយុត្តិដោយឥតគិតថ្លៃដល់កុមារ រួមមាន៖

- **ការប្រឹក្សាផ្នែកច្បាប់៖**

នោះគឺជាការដែលកុមារបានអ្នកអនុវត្តផ្តល់ជំនួយគតិយុត្តិ ផ្តល់ការណែនាំ ផ្តល់យោបល់ និងជួយរៀបចំឯកសារពាក់ព័ន្ធនឹងវិវាទ ប្តឹងតវ៉ា និងបញ្ជូនទាក់ទិនដល់ច្បាប់ ព្រមទាំងណែនាំឲ្យភាគីពាក់ព័ន្ធធ្វើការផ្សះផ្សា ចរចា និងឯកភាពលើការដោះស្រាយកិច្ចការ។

- **ការចូលរួមក្នុងនីតិវិធី៖**

នោះគឺជាការដែលកុមារទទួលបានការការពារ សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ក្នុងសំណុំរឿង ព្រហ្មទណ្ឌ រដ្ឋប្បវេណី រដ្ឋបាល និងវិស័យច្បាប់ផ្សេងៗទៀតពីភ្នាក់ងារជំនួយការគតិយុត្តិ (លើកលែងតែវិស័យអាជីវកម្ម និងពាណិជ្ជកម្ម)។

- **តំណាងក្រៅនីតិវិធី៖**

នោះគឺជាការដែលកុមារទទួលបានជំនួយពីភ្នាក់ងារជំនួយគតិយុត្តិនិងមេធាវីដែលអនុវត្តការផ្តល់ជំនួយនីតិវិធីតំណាងក្រៅនីតិវិធីនៅចំពោះមុខស្ថាប័នរដ្ឋដែលមានសមត្ថកិច្ច។

សិទ្ធិរបស់កុមារ ក្នុងវិស័យជំនួយនិតិវិធី

យោងតាមបទប្បញ្ញតិក្នុងមាត្រា ៨ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ កុមារមានសិទ្ធិទទួលបានសិទ្ធិដូចជាមុខសញ្ញាបានជំនួយគតិយុត្តិ នោះគឺ៖

- ទទួលបានជំនួយគតិយុត្តិ ដោយមិនត្រូវបង់ថ្លៃសេវា ផ្តល់ផលប្រយោជន៍ជាសម្ភារៈ ឬផលប្រយោជន៍ផ្សេងៗ។
- ទទួលបានជំនួយគតិយុត្តិ ដោយមិនត្រូវបង់ថ្លៃសេវា ផ្តល់ផលប្រយោជន៍ជាសម្ភារៈ ឬផលប្រយោជន៍ផ្សេងៗ។
- ទទួលបានព័ត៌មានអំពីសិទ្ធិក្នុងការទទួលបានជំនួយគតិយុត្តិ នីតិវិធីនិងបែបបទនៃការផ្តល់ជំនួយគតិយុត្តិនៅពេលមកកាន់អង្គការអនុវត្តជំនួយគតិយុត្តិ និងស្ថាប័នរដ្ឋពាក់ព័ន្ធ។
- ស្នើសុំរក្សាការសម្ងាត់អំពីខ្លឹមសារកិច្ចការជំនួយគតិយុត្តិ។
- ជ្រើសរើសអង្គការអនុវត្តជំនួយគតិយុត្តិ និងភ្នាក់ងារជំនួយគតិយុត្តិនៅក្នុងតំបន់ដែលមានឈ្មោះក្នុងបញ្ជីប្រកាសជាសាធារណៈ ហើយស្នើសុំផ្លាស់ប្តូរភ្នាក់ងារជំនួយគតិយុត្តិ តាមបទប្បញ្ញត្តិនៃច្បាប់។
- ផ្លាស់ប្តូរ ឬដកពាក្យស្នើសុំជំនួយគតិយុត្តិ។
- បានសងសំណងចំពោះការខូចខាតស្របតាមបទប្បញ្ញត្តិ។
- ប្តឹងតវ៉ា និងបរិហារទោសអំពីការផ្តល់ជំនួយគតិយុត្តិស្របតាមច្បាប់ជំនួយគតិយុត្តិ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធផ្សេងៗ។



តើអ្នកណាអាចស្នើសុំជំនួយគតិយុត្តិសម្រាប់កុមារ?

យោងតាមបទបញ្ញតិក្នុងមាត្រា ៨ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ បុគ្គលដូចខាងក្រោមអាចស្នើសុំជំនួយគតិយុត្តិសម្រាប់កុមារបាន៖

- កុមារអាចស្នើសុំដោយខ្លួនឯង។
- សាច់ញាតិ (ដូចជា ឪពុកម្តាយ ជីដូនជីតា និងសាច់ញាតិផ្សេងទៀត)។
- ស្ថាប័ន និងអ្នកមានសមត្ថកិច្ចអនុវត្តនីតិវិធី (ដូចជា នគរបាល អយ្យការ និងតុលាការ)។
- ស្ថាប័ន អង្គការ និងបុគ្គលផ្សេងទៀត (ដូចជា អាណាព្យាបាល គ្រូបង្រៀន អ្នកជិតខាង កម្មាភិបាលឃុំ និងអង្គការសង្គមជាដើម)៕

